**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៧៦១/២៤ ក.ប/ខ.ល

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា**

**និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** ក្នុងឱកាសទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ***«ភាពជាអ្នកដឹកនាំ និងការកសាងសន្តិភាព»*** ពីសាកលវិទ្យាល័យ ដុងហ្គុកវ៉ាយស៍ ( Dongguk University WISE ) នៃសាធារណរដ្ឋកូរ៉េ។

ការទទួលបាននូវសញ្ញាបត្របណ្ឌិតកិត្តិយស ***«ភាពជាអ្នកដឹកនាំ និងការកសាងសន្តិភាព»*** ដែលត្រូវបានប្រគល់ជូន **សម្តេចអគ្គមហាសេនាបតីតេជោ** នាពេលនេះគឺពិតជាស័ក្តិសមបំផុតចំពោះគំរូវីរភាព ការខិតខំប្រឹងប្រែង និងគុណបំណាច់ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** ក្នុងនាមជាអគ្គមគ្គុទេសក៍នយោបាយដ៏ឆ្នើម នៃព្រះរាជាណាចក្រកម្ពុជា ដែលមានភាពចាស់ទុំផ្នែកនយោបាយ មានភាពប៉ិនប្រសប់ ឈ្លាសវៃ ក្នុងទំនាក់ទំនងនយោបាយទាំងនៅលើឆាកជាតិ ឆាកតំបន់ និងឆាកអន្តរជាតិ ជាពិសេសការដាក់ចេញនូវ «នយោបាយឈ្នះ-ឈ្នះ» ដែលបាននាំមកនូវការបង្រួបបង្រួមជាតិ សុខសន្តិភាព ស្ថិរភាព នយោបាយ ឈានឆ្ពោះទៅការអភិវឌ្ឍជាតិលើគ្រប់វិស័យ។

ឆ្លៀតក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**